# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៣៧៧.សសរ

## សេចក្ដីសំរេច
### ស្ដីពី
### ការបង្កើតក្រុមការងារ សំរាប់ចុះទៅពិនិត្យដីមួយកន្លែង ដែលមានទីតាំងនៅអតីតមណ្ឌលទទួលជនធ្វើមាតុភូមិនិវត្តន៍កងវ៉ា ឃុំកំពង់ស្វាយ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ

៚៚✱៚៚

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សម្រេច

**ប្រការ១ :** បង្កើតក្រុមការងារមួយសំរាប់ចុះទៅពិនិត្យដីមួយកន្លែងដែលមានទីតាំងនៅអតីតមណ្ឌលទទួលជនធ្វើមាតុភូមិនិវត្តន៍កងវ៉ា ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- លោកជំទាវ | យូ អយ | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ប្រធាន |
| ២-ឯកឧត្តម | ឃួន រ៉ានីន | អគ្គនាយកកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៣-លោក | អ៊ិត រ៉ាឌី | អគ្គាធិការរង ក្រសួងយុត្តិធម៌ | សមាជិក |
| ៤-លោក | ម៉ុក សារុយ | អភិបាលរងទី៣ ខេត្តបន្ទាយមានជ័យ | សមាជិក |
| ៥-លោកស្រីឧត្តមសេនីយ៍ត្រី | អ៊ុន សុគន្ធា | ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ | សមាជិក |
| ៦-លោក | ហ៊ុយ ផាប់ | អនុប្រធាននាយកដ្ឋានអភិរក្សសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

**ប្រការ២ :** ក្រុមការងារនេះមានភារកិច្ច សហការជាមួយអាជ្ញាធរដែនដី គ្រប់ថ្នាក់ដែលពាក់ព័ន្ធ ចុះទៅពិនិត្យស្រាវជ្រាវដល់ទីកន្លែងផ្ទាល់ និងប្រមូលឯកសារសំខាន់ៗ និងពត៌មានជាក់ស្តែង ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

**ប្រការ៣ :** សមាជិកទាំងអស់របស់ក្រុមការងារ ត្រូវចូលរួមប្រជុំ និងចុះបំពេញភារកិច្ចតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការបណ្តាក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមាន ឈ្មោះក្នុងប្រការ ១ មានភារកិច្ចទទួលអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**<u>កន្លែងទទួល:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនិងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ-កាលប្បវត្តិ